ចាងហ្វាង- „តែក្តី ចុងចម្លើយចូលស្តាប់សេចក្តី យើងតុលាការនៅក្រោមបង្គាប់ច្បាប់ ដែលយើងនឹងកាត់សេចក្តីនេះត្រូវកាត់តាមគតិច្បាប់ៗបង្គាប់ឲ្យគៀប តាមពាក្យចុងនឹងពាក្យចម្លើយ យើងបានគៀបហើយឃើញជាគូក្តីមួយប្រកាន់ មួយប្រកែក ត្រូវយកសាក្សីបំពេញកំឡាំងតាំងសន្ធាន ចុងយកខ្លួនឯងជួយជាសាក្សីត្រង់នេះច្បាប់មិនហាមឃាត់,,

## ចម្លើយមានសាក្សីៗឆ្លើយសមប្រកបតាមអាង

យើងជាតុលាការត្រូវយកច្បាប់ជាប្រមាណ ព្រោះយើងគ្មានញាណសម្រាប់ឲ្យដឹងជាក្តី ខាងណាត្រង់នឹងវៀចបានទេ ត្រូវតែយកតាមកំឡាំងក្តី ដែលមានសាក្សីគ្រប់បរិបូណ៌ចូនៗ ឯរឿងនេះសោត ក៏ជាការប្លែកខុសពីរឿងធម្មតា តុលាការបានតាំងចិត្តជាសុចរិតយុត្តិធម៌ មិនលុះតាមអគតិទាំង៤ប្រការ គឺ ឆន្ទា ទោសា ភយា មោហា លំ



អៀងចូលទៅខាងណាទេ ។

## វិនិច្ឆ័យសេចក្តី

ឲ្យចម្លើយឈ្នះចោទ ត្រូវបដិសេធបណ្តឹងចោទជាអសារ ហើយឲ្យចោទបង់ថ្លៃជូនក្រាដែលប្រជាប់ ព្រមតាំងប្រជាប់ក្តី នឹងឲ្យសងជម្ងឺចិត្ត បំលុបខ្មាសស្រីជាចុងចម្លើយ តាមចំនួនដូចបានតាមលំដាប់ ចាក្រាក្រមមសករិយោ តែត្រូវបើកឧទ្ធរណ៍ ៣ ខែគិតតាំងពីថ្ងៃកាត់សេចក្តី ។

## ចុះតាមលេខាតុលាការ

ហ្វូង- ‘ បាទព្រះតេជព្រះគុណ បានវិនិច្ឆ័យសេចក្តីនេះ ត្រូវណាស់ តែត្រូវនឹងច្បាប់ នៅមិនទាន់ត្រង់ក្នុងគតិយុត្តិធម៌និងគតិលោកទេ ព្រះតេជព្រះគុណនឹងយកច្បាប់ជាប្រមាណមិនទាន់ត្រូវទេ គួរនឹងយកគតិធម៌ជាធំ

ផុត គតិលោកបន្ទាប់ គតិច្បាប់ជាចុង ព្រោះគ្រប់ប្រទេសក្នុងលោក ប្រើច្បាប់មិនដូចគ្នាទេ មានខុសគ្នាច្រើនណាស់ ឯគតិធម៌មិនចេះខុសគ្នា ។

## គតិធម៌នោះយ៉ាងណាបានជាថាមិនខុសគ្នា

ពោលខ្លី កើតមកជាមនុស្សឬសត្វតែងស្រឡាញ់សេចក្តីសុខដូចគ្នា គ្មាននរណាប្រាថ្នាចង់បានទុក្ខទេ ការមិនបៀតបៀនគេឲ្យគេមានទុក្ខ ទើបជាធម៌រៀបឬកក្រក់ គ្មាននរណាស្រឡាញ់សោះ ចំពោះគេស្រឡាញ់តែគ្រន់ធឹងល្អ ។

ខ្ញុំបាទស្រឡាញ់ណាស់ បានជាប្តឹងសុំឲ្យព្រះតេជព្រះគុណរកឲ្យឃើញគ្រន់ធឹងទៀត ឥឡូវព្រះតេជព្រះគុណជាគ្មានញាណចក្ខុបានជាយកច្បាប់ជាប្រមាណ ឯចំណែកខ្ញុំបាទយល់ថា ញាណចក្ខុមានគ្រប់គ្នាទាំងអស់ ខុសតែមានច្រើនធឹងតិចប៉ុណ្ណោះ សូម្បី



សត្វតិរច្ឆានក៏ដូចជាមានដែរ បានជាស្រមោចក៏រកទៅរកស្ករឃើញ ឯរឿងខ្ញុំបាទសួរព្រះតេជព្រះគុណទីកន្លល់ខ្លះ ជាហេតុដូចម្តេចបានជាខ្ញុំបាទជាមនុស្សវិកលចរិត គួរនឹងសើបឲ្យល្អិតក្រៃតែធឹង ការសើបទៅធឹងហ្នឹងហើយជាគន្លងដើរទៅកាន់ញាណចក្ខុនោះ ឯព្រះច្បាប់សំកប់ផែនដី លោកគ្រាន់តែតាំងជាគោលតារាកឲ្យជាប់ញញើតកោតខ្លាច មិនមែនឲ្យតុលាការ ប្រើអំណាចខ្លួនឲ្យស្មើនឹងច្បាប់នោះ កាលណា លោកឲ្យប្រើគំរូប្រាជ្ញាខ្លួនរបស់ខ្លួនជាប្រមាណ ។

ខ្លួនត្រូវប្រើសន្តានចិត្ត ឲ្យត្រង់ក្នុងយុត្តិធម៌ បើសេចក្តីទុញតាល់ឲ្យពិសោធសើបសួរយកការក្រៃតែក្លយល់ស្គាល់ទៅខ្លះ ។

រឿងខ្ញុំបាទ ១ ចង់ឲ្យលោករកឲ្យឃើញច្បាស់ថាខ្ញុំបាទនេះជាមនុស្សវៀច ប្តឹងបង្កាច់គេ បើឃើញ

សេចក្ដីវៀចនោះ លុះតែខ្ញុំបាទទទួលដឹងថាខ្លួនវៀចមែន
រួចសុំយកសេចក្ដីឃើញនោះ ទៅបំពេញលើសេចក្ដី
ត្រង់ខាងចម្លើយ ដោយកំឡាំងសាក្សីទៀត ដូច្នេះទើប
សមគួរ និងគតិយុត្តិធម៌ ពេលនេះព្រះតេជព្រះគុណ
គ្មានកេតិ៍ខ្វៀចត្រង់ខាងខ្ញុំសោះ ស្រាប់តែកាត់ឲ្យ
ចម្លើយឈ្នះ បដិសេធបណ្ដឹងខ្ញុំបាទជាអសារ ខ្ញុំបាទ
យល់ថាលោកជាតុលាការខ្ជីខ្ជា ធ្វើការដូចគេគ្រាន់ស
អក្ដិបង់ខ្លាច ពុំនៃតតុលាការវេតខុស ពុំនៃត
មានសាលព្រះកញ្ញាជាន់ខ្ពស់ ចាំរុះរើថ្មីឡើងទៀត មិន
ឃើញទុក្ខព្រួយបន្សៀតកន្ត្រាសជាសម្បត្តិផែនដី បាន
សេចក្ដីក្ដៅក្រហាយ ។

បុកណាចាប់ចាំងឡាយ លោកឲ្យតុលាការជាប់
តាមការរបស់កូនក្ដី ដែលចូលកាន់សាលាគឺជាសេចក្ដីក្ដៅ
ចំពុះមាតាបិតាក្រឡេកឃើញមុខបុត្រ ។ ដូចនឹងគេចុះទៅ



ទទួលទុបថែបប៊ ឲ្យដឹងជានរណា គេបំភិតបំភ័យនឹងជួយ
ការពារ គេមិនមែនហាមមិនឲ្យចូលទៅមុខ ទុកចំហ
ទ្វារក្រោយឲ្យឡើងដូច្នោះទេ ព្រះតេជព្រះគុណក្រង់
ណាស់ តែពួកក្រុមរបស់ព្រះតេជព្រះគុណមិនមែនដូចគ្នា
សុទ្ធតែឃើញកូនក្ដីជាចំណីខាំចំពាស៊ីផឹកព្រឹកល្ងាចបានក្លាយ
បើមិនដូច្នោះគង់ចុះកំហិតកំរាមពុំទទួលទីកមុខ មកពេល
ព្រឹកជាល្ងាចដាច់ខូចស្រោ ហើយយ៉ាំនណា ។

ព្រះតេជព្រះគុណជាតុលាការ កាត់ឲ្យខ្ញុំបាទចាញ់
ចម្លើយដូច្នេះ ខ្ញុំបាទអាណាស់ព្រោះត្រូវចំណាយចិត្ត ផ្សែក
ខ្ញុំបាទចង់ឲ្យរឿងនេះបានគេដឹងច្បាស់ខ្លួនទៅ ក្នុងប្រទេស
កម្ពុជា ឲ្យឃើញថានរណាវៀច នរណាត្រង់ បើ
ឃើញថាខ្ញុំបាទវៀចប្ដឹងចង់ឲ្យគេខូចកេរ្តិ៍ឈ្មោះ សុំឲ្យ
សាលាជាន់ខ្ពស់ចុះទោសជាទម្ងន់ចុះ នឹងបានទុកឈ្មោះក្នុង
គន្លងការបុកណបានចំនុកទុកមកថា " មនុស្សណាបាន

ឈ្មោះឲ្យគេចុះក្នុងពង្សាវតារ ទើបពេញជាមនុស្ស ទោះអាក្រក់ក្តីល្អក្តីមានដំឡៃដូចគ្នា ,, ។

ហេតុដែលខ្ញុំបាទនាំមកពណ៌នាខាងលើដូចជារំលឹកប្រដៅលោកអ្នកធំ ពុំដូច្នោះទេខ្ញុំបាទសូមអភ័យទោស ព្រោះចិត្តខ្ញុំបាទអាណិតចុងចម្លើយបើព្រះតេជព្រះគុណបញ្ជូនខ្លួនទៅហើយ ដោយខ្ញុំបាទឧទាហរណ៍គ្នាក៏គង់ពោលផ្ទះសម្បែងកន្លែងឋាន បានពីណា នឹងនៅក្បាលខ្លួនមិនសូន្យអន្ត-រាយទ្រព្យសម្បត្តិអស់ទៅហើយឬ ? ។

ចៅហ្វាយ - បានៗ ហ្វុងសក្កាជាសត្វគ្រប់ក៏ទុនសញ្ញាប់នៅលើតុ នឹកខ្មាសហ្វុងសក្កាព្រោះខ្លួនចាត់ការមិនទាន់ចូលក្នុងបទយុត្តិធម៌មែន ឃើញថានឹងកែប្រែពុំបានព្រោះកាត់សេចក្តីរួចទៅហើយ ទើបថា «បើលោកក្មួយទទួរណ៍ នឹងឲ្យបញ្ជូនសំណុំរឿងនឹងខ្លួនក្តី ចូលទៅទីសាលព្រះអាជ្ញាវេលាណា ?»



ហ្វុង — «បាទ, សូមព្រះតេជព្រះគុណបង្អង់សិនចុះ ព្រោះខ្ញុំបាទនៅរៀបចំស្រុកទេសពុំទាន់រៀបរយ ចាំដាក់គយល្បាតលាតក្រៃលែងឲ្យមាំមួនសិន បើលោកមេកងធំ បង្គាប់ឲ្យលើកទ័ពចូលទៅក្រុងថ្ងៃណា នឹងជូនដំណឹងឲ្យបញ្ជូនទៅបន្ទាន់គ្នា ឯហ្វុងសក្កានៅធ្វើទ័ពមុនប្តឹងរឿងនេះអស់រឿង ៦ ខែ ក្រោយប្តឹងនៅរៀបចំស្រុក ៦ ខែគ្រប់ជា ១ ឆ្នាំ មុននឹងលើកទ័ពទៅ. បានឲ្យបំរើទៅជំរាបដំណឹងឯសាលាខេត្ត ឲ្យបញ្ជូនសំណុំរឿងនឹងខ្លួនចម្លើយចូលទៅក្រុងលង្វែក ក្នុងពេលលើកទ័ពទៅ»

## វគ្គទី ១៧

សាលព្រះរាជអាជ្ញា បានទទួលសំណុំរឿងនឹងខ្លួនចម្លើយ ហើយក៏បានចេញដីកាហៅខ្លួនហ្វុងសក្កាទៅប្រាប់ថា តុលាការបានពិនិត្យក្នុងសំណុំរឿងហើយ ឃើញថាត្រូវឲ្យសាលាខេត្តបន្ទាយមាសរៀបសេចក្តីស៊ើបសួរឲ្យច្បាស់

ថាហ្វងស្កាមានកំពែងឈ្មោះធាំងសារិកាមែនឬទេ ? កាលហ្វងស្កាមិនទៅទៅបារាំង ធាំងនោះបានបញ្ចេញក្បត់ នាំពង្រត់គ្នាទៅបាត់មែនឬទេ ? បើបានសេចក្តីឲ្យបញ្ជូនមកសានអាជ្ញាកាត់សេចក្តីឲ្យគ្រប់ក្តីថយទៅនៅតាមទីថានពង់ខ្លួន ។ ឯថាំងហ្វាំងសាលាអាជ្ញាជាតួកក្រុមសម្តេចចៅហ្វា ។

កាលហ្វងស្កាបញ្ចេញជំនោរលើកទ័ពទៅបារាំងនឹងប្រទេសយួន បានចំនួនកន្លះខែ សម្តេចចៅហ្វាឲ្យរៀបសង់ជំណាក់ ២-៣ ខ្នងភ្ជាប់នឹងផ្ទះធំ មានបន្ទប់ច្រើនក្នុងគឺបន្ទប់ដេក បន្ទប់ទឹកនឹងល្វែងបរិភោគអាហារ មានគ្រែតុ : ទូកៅអី របៀបរបស់ក្បូរ លុះបាត់ការរៀបចំរួច ហើយឲ្យរើសក្មេងជំទង់ក្រមុំល្អៗ មកជួលគ្រូបង្ហាត់ឲ្យច្រៀង រាំបាំមហោរី ជាទីក្រសាលសប្បាយ មនុស្សម្នាទាំងឡាយ សឹងចូលទៅមើលគ្រប់ទិវារាត្រី សម្តេច



ចៅហ្វាបានឲ្យអញ្ជើញនាម៉ឺនមុខមន្ត្រី សេដ្ឋីអ្នកមាន ចូលទៅមើលកំសាន្តសប្បាយរាល់ៗ ថ្ងៃ ។

កិត្តិសព្ទនោះក៏ជ្រាបទៅដល់ព្រះករុណាជាម្ចាស់ផែនដី កាលសម្តេចចៅហ្វាចូលទៅគាល់ ក្នុងពេលថ្ងៃមួយទ្រង់មានព្រះតម្រាស់សួរសម្តេចចៅហ្វាថា : ខ្ញុំឮថាសម្តេចមានស្រីរបាំរាំច្រៀងល្អស្អាតណាស់មែនឬទេ ?,,

សម្តេច « ព្រះករុណាពិសេស មានមែន តែមិនល្អនឹងពិរោះពិសារស្មើនឹងរបាំព្រះរាជទ្រព្យទេ គ្រាន់តែលបកាមញ៉ាក់ខ្ញុំព្រះរាជការ » ព្រះករុណា - តាំងថ្ងៃណាខ្ញុំនេះ ខ្ញុំនឹងទៅមើលបានឬទេ ? ,,

សម្តេច ព្រះករុណាពិសេស បានណាស់ ថែមតាំងពេញអំណររេរ នឹងព្រះតេជព្រះគុណល្អនគូលព្រះបានទតទីមន្ទីលសួស្តី ,,

ព្រះករុណា - " ថ្ងៃណាខ្ញុំនឹងទៅបាន ?

សម្តេច – "ព្រះករុណាពិសេស យូរណាស់ត្រឹម ៧ ថ្ងៃទៀតខ្ញុំព្រះអង្គនឹងរៀបក្បួន មកទទួលស្តេចព្រះរាជដំណើរជាទីគួរសម" ។

ព្រះករុណាយាងចូលក្នុងព្រះរាជបន្ទប់ក្នុងខណៈនោះ សម្តេចចៅហ្វាអរណាស់ប្រៀបដូចគេបានហោះ ទៅលើអាកាសវេហាស៍ ឬដូចគេបានទៅដល់ឋានសួគ៌ជាទីបិត ព្រោះត្រូវនឹងបំណងចិត្ត ដែលគិតទុកមកយូរថ្ងៃហើយ កាលថយទៅដល់ទីឋានបានឲ្យរៀបចំទីដំណាក់ ឲ្យស័ក្តិសមនឹងបន្ទំក្សត្រ ចាត់បំរើឲ្យទៅយករបស់ដែលត្រូវការពីទីឆ្ងាយ ៗ បានស្រេចស្រាប់ ចាត់ឲ្យប្រុងប្រៀបប្រដាប់ក្នុងទីគេហដ្ឋានបានជួនបរិបូណ៌គ្រប់ ៗ

លុះដល់ពេលប្រលប់ថ្ងៃជាគំរប់ ៧ សម្តេចចៅហ្វាក៏ចូលគាល់ព្រះករុណា អញ្ជើញស្តេចឲ្យយាងគង់ព្រះរាជរថ របស់ព្រះរាជទ្រព្យ នឹងរថសេះខ្លួនជាលំដាប់ ៧



រថ ព្រះករុណាក៏ទ្រង់យាងព្រមដោយពួកនាងស្រីគ្គាបរិការទៅដល់ទីគ្រិហា សម្តេចចៅហ្វាទទួលជារៀបស្កកស្កម្ម សមនឹងកិត្តិយស មានរាជបល្ល័ង្កតាំងក្នុងជាន់ខ្ពស់ជាទីគង់មានវាំងននរ៉ង ជាបន្ទប់មន្ត្រីគាល់ ហៅ មានកន្លែងនាងកណ៌ហៅ នឹងស្នំក្រមការនារី គាល់ពីក្រោយដំណាក់ក៏វៃនលយចូលទៅដល់ ក្រឡាព្រះបន្ទំ នឹងកន្លែងព្រះស្នំក្រមការ សម្តេចចៅហ្វាក៏អញ្ជើញព្រះករុណាចូលទតព្រះនេត្រ ៗ

កាលព្រះករុណាយាងចូលដល់ល្វែងក្រឡាបន្ទំទទួល នាងចន្ទ សុជាក្មួយសម្តេចចៅហ្វា ចេញពីបន្ទប់មួយ មកថ្វាយបង្គំព្រះករុណាជិតព្រះបាទា ព្រះករុណាត្រាស់សួរសម្តេចចៅហ្វាថា "នាងនេះជាអ្វីនឹងលោក ?"

សម្តេច – "ព្រះករុណាពិសេស នាងនេះជាក្មួយខ្ញុំព្រះអង្គបង្កើតបានយកមកចិញ្ចឹមតាំងពីតូច ឈ្មោះចន្ទសុជា

អាយុ ១៦ ឆ្នាំ ,, ។

ព្រះករុណា – ,, នាងនេះមានរូបភាពល្អណាស់ លោកឲ្យមានស្វាមីហើយឬនៅ?"

សម្តេច – " ព្រះករុណាពិសេស ,, មិនទាន់ឲ្យមានស្វាមីទេ ព្រោះបំរុងទុកថ្វាយទតព្រះនេត្រ បើទ្រង់សព្វព្រះហឫទ័យនឹងលើកថ្វាយ ;,

ព្រះករុណា - លោកប្រាកដជាទុកឲ្យមែនឬ?

សម្តេច – "ព្រះករុណាពិសេស, ពិតមែនបានជាកាត់តែងទីនេះទុកថ្វាយក្រសាល ,,

ព្រះករុណា – "ឱលោកមានអធ្យាស្រ័យល្អណាស់ ខ្ញុំសូមអរគុណលោក"

សម្តេច – "សូមព្រះរាជទាន ចូលស្រង់ព្រះទឹកកៅរួចសោយក្រយាហារ ខ្ញុំព្រះអង្គបានបំរុងជាស្រេច,.

សម្តេចចៅហ្វាក៏អញ្ជើញស្តេចចូល ទៅក្នុងល្វែងក្រ



ឡាព្រះបន្ទំ ឲ្យនាងចន្ទសុដាចូលតាមទៅបំរើបម្រះ យកព្រះក្លសាផ្កាលំចូលស្រង់ក្នុងបន្ទប់ នាងក៏ធ្វើសេចក្តីគោរពផងទឹកថ្វាយ ហើយចូលទៅដុសព្រះមលាទូរ ព្រះបាទយាងស្ងួតគអៀនអន់ ព្រោះមានគ្រូបង្គាប់គ្រប់គ្រាន់មកច្រើនថ្ងៃហើយ ឯទឹកស្រង់នោះសម្តេចចៅហ្វារើសយកគ្រប់ណាៗ មកធ្វើដោយជាំនឹងមន្តគាថាគមក្រិតយាស្នេហ៍មុខដាក់ឲ្យ ព្រះអង្គទ្រង់វង្វេងស្រឡាញ់នាងចន្ទសុដា ឯនាងចន្ទសុដាក៏បេះធ្វើកិរិយា ឲ្យហួងហ្សងព្រះទ័យអាល័យស្រឡាញ់ពេញទី កាលទ្រង់ស្រង់ទឹកកៅរី ហើយសោយព្រះក្រយាហារស្រេចកាលណា ទ្រង់ចូលក្រឡាព្រះបន្ទំរួមសមសេនឹងនាងចន្ទសុដានារី ។

បណ្តាពួកបាំមហោរី ក៏ច្រៀងទទួលចង្វាក់ភ្លេងល្វេងល្វើយស្រណោះ ឯចំនុកច្រៀង នោះសម្តេចចៅហ្វាតែងរៀបបានខាងក្រោមនេះ ។

## បទដកសយសុវណ្ណ

ចន្ទអើយចន្ទចរសេប្រផូរ ចន្ទពេញពេញបូណ៌មី
ថ្វា នៅលើអាកាសហ្វសហត្ថា ប្រវាទិនកាន់ចន្ទមិនដល់ ។
មិនដូចតួផ្ទសុជា នៅជិតហត្ថាលាលើកថ្កល់
ដាក់លើទ្រូវកំណល់ សែនសល់កំនាប់ដាប់សមសេ ។
ព្រះអើយព្រះអគ្គីន្ទ្រទេព ក្រុងកម្ពុជាធានីស្មោះ បាន
ចន្ទសុជាគូសម្លស្ស ផន្សាសោម្យស្រស់ស្រស់ថ្មានថ្មី ។
មុខគួរគេមប្បន្ទុំដាប់ បន្ទាប់ទៀបអគ្គពន្សប្រក្រី បន្ទា
ទុក្ខសោកកេតលោកិយ៍ បន្ទីដំពាំងស្រីថ្លៃសុជា ។
សុដង់គង់ចិត្តបែកបែក ទបរូបនៃបតិតជិតធុក ទូ
គូរនែពាំងខ្ទេហារ ម្ចុំហត្ថក្សត្រាការគៀតកិត ។
ទសយសុវណ្ណចន្ទសុជា គួរណាស់ជ្រះថ្លាប្រើទឹកចិត្ត
ប្រណម្យព្រមថ្វាយកាយប្រណិត ឲ្យទ្រង់គង់ស្ថិតស្ថិទ
កុណ្ឌី ។ បើនាងដាងបេះរះពាត់ការ ថ្វាត់ថ្វាយដោយ

សារព្រៃថ្នាស្រី មិនមើលបំណាំសបបក្រី ព្រោសញ្ញ៉ី
មហោសិខ្ញុំអស្ចារ្យ ។

## សក្ការិទ៌

សក្កាវ៉ីអគ្រាគ្រស្វាត់សត្វដេក ទៅតាមដំណេក
មែកព្រឹក្សា នៅកែសុវណ្ណចន្ទសុជា សេយ្យនាក្សា
ក្សាក់ពេកស្បៀយ ។
រ៉ៃយការគោរពអក្កាទ គូនាថដាក់បមពុំខ្វាប
ទៀយ ថ្វាយចិត្តបុប្ផាពិដោរល្អើយ ទ្រង់ស្បៀយ
ខ្សែខ្សែនក្កន្តាអើយ ។
សក្កាវ៉ីទណាមន្ទាទិញ មាឲយូបស្រពាប់ទបអប់
កេក្ខូស្បូសេត្វក្រេបពាប់ផ្កុំ បុប្ផាក្រពុំពុំទៅធ្លាយ ។
ចាំពេលដែលកែបែកបុស្សា អេចិត្តកេក្ខូស្បូសត្វ
សាយ ដូចព្រះចក្រពន្សទ្រង់គៀកកាយ សប្បាយ
ដោយសារសុជាអើយ ។

សក្ការទ័ទុចខ្ញុំអន្ទលិគ្គ   គ្មិនតែក្រើថ្មស្រអាប់
ឯខ្ញុំសុជាថ្វាក្ខុតាប់   ពុំប្រែក្រឡាប់គ្រប់យប់ថ្ងៃ ។

ប្រើសគ្រង់វង់វណ្ណខ្ញុំសុជា   សំពប់ព្រមហាក្យគ្រ
ថ្វាថ្ងៃ   ខ្ញុំអើយខ្ញុំគួនជួនដកម៉ែ   គួគួរប្រោស្រ័យ
ឲ្យស្អប់អើយ ។

សក្ការទ័ទុចខ្ញុំណ្ណាស្រស់   ជន្យាសោឡសបន្ទស់
ស្រី   នៅឋានេះឆាងឆើតព្រោះតើតថ្មី   មានបុំរៃដប
បេះគ្រិបធ្លាក់ ។
នៅដេត្រុំប៊ុផ្ជាបុសបុន   ដីបបុនវង់សុំក្រពុំចាក់ក្បាច់ក្បូរ
ក្វៃទេសមិនទ្វេសថ្នាក់   ដូចហាក់បក្រដើរប្រសើរអើយ ។

ព្រះបាទសម្តេចព្រះរាមា   ពជាតិបតីជាម្ចាស់   ព្រះ
អគ្គគ្រវ់សេហ៍មន្ត្រីរើយា   ឡូនវៃឡូងឺនចន្ទុស្បាក្ដយ
សម្តេច   ចៅហ្វ៊ាបោះបន់ការគ្រួតត្រាពជការផែនដី   អស់
រៀង ១ វៃ១   តែនៅក្នុងដំណាក់ផ្ទះសម្តេចចៅហ្វ៊ា



ក្រោយនោះ   ទើបព្រះអគ្គលីលាទៅគង់ក្នុងបរមរាជវាំងវិញ
ទ្រង់តាំងនាងខ្ញុំសុជា   ជាទីព្រះម្នាងផលចិត្តសុវណ្ណជំនួស
ទៅថមហាគា ។

កាលនាងខ្ញុំសុជា   តាមវៃព្រះករុណាទៅនៅក្នុង
ព្រះរាជវាំងនោះ   សម្តេចចៅហ្វ៊ាបានឲ្យគ្រឿងមាស ១
គ្រឿង   គឺកន្ធារ   ចិកោតានព្រះស្រីផ្គល   ដើងពានបារី
សុរីសុទ្ធមាស   តែរបស់ទាំងអស់នោះ   ជារបស់ខ្ញុំ
លួចព្រះរាជទ្រព្យ   កាលលោកនៅធ្វើជាតានហ្វានឃ្លាំង
តែលបគ្រាមកុដធ្លាក់ជាគ្រាក្បាលពហូ   ព្រះនាកយណាំបែង
កាគគងពីលើឯត្រង់តែមពានព្រះស្រីទីងរបស់ឯទៀតសុទ្ធ
តែមានអក្សរ   'រ,   នៅជុំវិញមាត់តែមបើមិនសង្កេតក៏
ស្គាននៅក្បាច់ក្បូគ្រង់នោះ   សម្តេចចៅហ្វ៊ាមិនដឹង   មិន
បានឲ្យជារក្រោយមែកលុបចេញនៅតួ (រ) ជុំវិញ ឯតួ (រ)
គឺកមាព្រះរាមាតិច័យ ។

ព្រះអង្គក៏ទ្រង់ថយព្រះកាយពលស្គមថ្គិបទៅ ព្រោះ តែត្អូញត្អែរថាឈឺព្រះកេសនឹងរិលព្រះភក្ត្រ ។ លោក កោសាធិបតី ជាមន្ត្រីចាស់ទុំកងផងការល្អ សុចរិតយល់ ឃើញថាព្រះករុណាឡូងឡែងនឹងនាងបន្ទូស៊ុំងា ដោយត្រូវ ស្នេហ៍មន្ត ក៏ចូលទៅក្រាបបង្គំគាល់ ហើយទូលបញ្ឆិត បញ្ឆៀងថា (ខ្ញុំព្រះអង្គយល់ឃើញថាព្រះករុណាស្គម ខុសប្រក្រតី បានឲ្យខ្ញាហោពេទ្យ នេត្រគន់គូរ ព្រះគ្រោះគេទាយថា មានអ្នកតាអស្សាស្រុកក្រុមមឿង ប្រើព្រាយកន្ទោងខ្មៅឲ្យធ្វើព្រះអង្គ ។ ច្រើនឈឺព្រះកេសា រិលព្រះភក្ត្រ ត្រូវឲ្យនិមន្តអ្នកយើង សូត្រមន្តស្រោចទឹក ទើបជា ។

ព្រះករុណា.- "យ៉ាលោកកោសា ខ្ញុំមិនជឿសោះ អ្នកតាខ្មោចបិសាចនោះ តែបើជាត្រូវខ្លះទៅដែរ ខ្ញុំបេះ តែឈឺក្បាលរិលបុខមែន,,



កោសា.- "ព្រះករុណាពិសេស, ដូចកាលបើមែន ទៅដែរខ្មោចបង្គ្រួមន្តគាថានោះ បើមែនមិនមែនត្រូវតែ ធ្វើឲ្យអស់ទៅ"

ព្រះករុណាថាតាមតែលោកគិតចុះ ។ លោក កោសា ធិបតីអាណាស់បានចាត់បំរើឲ្យទៅដល់ទៅហ្វាយស្រុកខេត្ត កំពត ឲ្យនិមន្តអ្នកយើងលាវ ១ អង្គ នៅគង់កំពូលភ្នំពពក វិល ព្រោះកម្មផលបែកណាមលោកយើលោក បាននិមន្តទៅ ដល់ក្រុងលង្វែក លោកកោសាបានប្រាប់ពិស្ដារពីការ ប្រឈួនព្រះករុណា ។

លោកអ្នកយើងដឹងថាព្រះអង្គត្រូវស្នេហ៍ ទើបតែកំ តាយឲ្យអស់ពិសមន្តក្រិតយា លោកបានចូលទៅសូត្រ មន្ត ស្រោចទឹកថ្វាយព្រះករុណា ។ ក៏ជាស្រឡះអស់ព្រះ គេតឈឺព្រះកេសរិលព្រះភក្ត្រា ទីងព្រះកាយាជាប្រក្រតី មនុស្សប្រុសស្រីកើតជ្រះថ្លាពេកណាស់លោកក៏រិលទៅកាន់ជាន

ប្រគុំភាគវិលវិញ មនុស្សគ្រប់ដំបន់កាន់អានស្រឡាញ់ ហៅជាលោកគ្រូគំរូដោយរៀបរាប់ហាក់និយាយជាភ្នំគំរូ ទាល់សម័យនេះ ។

## វគ្គទី ១៨

កាលលោកមេទ័ពលើកពលវិលពីច្បាំងនឹងចំពាយនូ មកដល់ក្រុង លង្វែក ហើយក៏បានរៀបបញ្ជីរាយឈ្មោះទាហាន សរសើរគុណបំណាច់ថ្វាយព្រះករុណា ក៏ទ្រង់ប្រោសប្រទានឲ្យរង្វាន់និងឡើងសក្តិតាមថ្នាក់ , ឯក ទោ , ត្រី បក្សា ។

ឯហ្លួងសក្តាព្រះករុណា ទ្រង់ប្រោសឲ្យឡើងយសសក្តិថ្នាក់ទីព្រះកាន់ពលមួយពាន់ (១) ។

ព្រះសក្តាវុធរង្វៃក្រ បានទៅឯផ្ទះតាពជ័យយាយតាពជាបិតាមាតាធម៌ ក៏សួរដំណឹងទៅចម មាតានិងព្រះកុ

(១) វរសេនីយត្រី



មារ ដឹងថាសុខ តែនៅក្នុងគុកជាទុក្ខវេទនា ដំណឹងព្រះករុណាក៏ពេជ្រសោះសូន្យគ្មានទឹកដល់ប្រពន្ធនិងកូនសូនសោះ ព្រះសក្តាយំសោកស្រណោះគាត់ឡើងករល័យក្រៃពេកណាស់ដល់បិតាមាតាដែលចាស់ ៗ តាំងពីថាពេលនេះជាកម្មទៅចមមាតានិងព្រះរាជកុមារ មិនឲ្យទ្រង់សប្បាយ ខ្ញុំបាទទៅច្បាំងស្រុកឆ្ងាយ អស់រយៈជាងមួយឆ្នាំ ហើយវិលមកវិញបានឡើងយសសក្តិពេញ ថ្នាក់អ្នកមាននាមសនា ព្រះករុណាប្រោសព្រះរាជទានឡើងជាមុខព្រះសក្តិ ៦ ហ៊ូពាន់ គួរឲ្យទៅចមមាតានិងព្រះរាជកុមារលោកបានទាន់ឃើញនិងជួបជួយគេកអរផង បុណ្យរាំសនាតែខ្ញុំបាទជាបងបានផ្ទុនពន់គន្ធង ខាងលោកជាប្អូនជាក្មួយខ្ញុំ ខ្ញុំបាទនឹកហើយនាំឲ្យតែព្រួយលំបាកក្នុងចិត្តស្ទើរនឹងមិនចង់ផ្ទុំដីតែឲ្យរស់នៅទេ ស៊ូរស្លាប់ជាខ្មោចទៅល្អជាជាង ។

តាយាយតាំងពីកើឈឺស្គម នៅតែកងស្ទើរខិន ក្រោកឡើងមិនរួច ទំផ្លូបនិយាយយំថា ណ្ហើយកូន ខ្លួនអ្នកមានបុណ្យរក្សាជាធំ ហើសលើសគេ កូន កុំស្ងៀមចំនេះទេទេសោះ ត្រូវតែកេប្រាជ្ញាជួយដោះ ប្អូនទឹងក្ឈមឲ្យរួចដោះដោយប្រាជ្ញាបានឯង ស្រាប់បិតាមាតា ចាំពេលណាតែនឹងស្លាប់ឆាប់ ៗ ហើយ ថាហើយក៏យំ ទាំងតានិងយាយ ព្រះសក្កាក៏ឆ្លើយថា សូមយាយនិយាយ ឲ្យជួបចិត្ត ថារឿងនេះមាតាបិតាកុំត្រូវព្រួយគិតពេកទេខ្ញុំ បាទនឹងគិតរកឧបាយជួយដោះឲ្យរួចឆាប់ ៗ ហើយ តាយាយឮដូច្នោះ ក៏ឡើងពីសារបាយបានក្រលពីរ នាក់ បានមួយស្របក់ មានបំរើពីកាប្រាសាលាកាន់ដើ កាទៅឲ្យព្រះសក្កា ថាព្រឹកស្អែកឲ្យអញ្ជើញទៅសាលា ស្តាប់សេចក្តីផង ។

លុះព្រឹកឡើង ព្រះសក្ការៀបខ្លួនទៅសាលា តា



យាយក៏សួរថាកូនមានរឿងកើតក្តីពីអ្វី ,,

ព្រះសក្កា – ‟ បាទ ខ្ញុំបាទកើតក្តីប្រពន្ធគេកេ ពោល ២ ឆ្នាំ ហើយ ក៏និយាយឲ្យតាយាយស្តាប់សព្វ គ្រប់ ហើយថាខ្ញុំបាទប្តឹងឲ្យតែឃើញរៀបគ្រង់ប៉ុណ្ណោះទេ មិនបែនប្រែទៅយកវិញកាលណា គេដាច់ស្នេហាពីឯង ទៅហើយ ,,

តាយាយ – „ កូនកុំយកវិញ ស្រីផិតប្តីក្រពីស្រី គេល្អគោក ,,

ព្រះសក្កា – ‟ បាទ , បាទ ខ្ញុំបាទមិនយកវិញ ទេ ថាហើយក៏ចុះទៅដី កាពាលស្អុះមកកាគ្រាន ហើយលិតជើងព្រះសក្កា ១ ក៏ចូលទៅសាលា ,, ។

## តុលាការតាំងប្រជុំកាត់សេចក្តី

លោកចាងហ្វាង សានព្រះរាជាជាអធិបតី ទៅក្រុម ៤ នាក់ ជាសុភា

ក្រឡាបញ្ជី ១

តាំងហ្វាង — " នៃព្រះសក្តាវុធរឿងក្រ ទិងទាន

បទាក ប្រលិតជាគូទោទ ចម្លើយទាំស្តាប់ពាក្យពិ

ការក្យា ផ្សិតសានព្រះរាជ្យជាសាលាជាន់ខ្ពស់ ក្រ

សួងទទួលណំបានទទួលសុំណុំរឿង ពីសាលាខេត្តបាសាក់,,

ព្រះសក្តា - - ទោទ

នាងបទាកទី ១ }
ព្រលិតទី ២ } ចុងចម្លើយ

ករណីយហេតុ ទោទជាប្រពន្ធរឹតក្បត់ចូលក្នុងបទ

កាផ្ស ទោសមផ្សឹម ។

សានព្រះរាជ្យ បានពិនិត្យហេតុ សេចក្តី

ហើយ ឃើញនាងទោទនៅខ្វះស៊ើបសាក្សីតាមន័យរបស់

តុលាការ ឥឡូវសាលាខេត្តបន្ទាយមាស



ឆ្លើយផ្ទួនពាក្យបានមកវិញថា ទោទមានករិយាឈ្មោះនាង

សារិកាបែន តែពេលដែលចេញពាក្យគេហដ្ឋាន មកធ្វើ

តាហ៍ខបញ្ចាំក្នុងក្រុង៦ខែ នាងសារិកាពាស់ឈ្មោះទិងមាតា

ចុះចេញទៅនៅផ្ទះបងប្អូន ពាស់ឈ្មោះទិងប្អូន ១ ដៀស

ទៅនៅទីដោយខ្លួនឯង នាងនោះនៅតែម្នាក់ឯងឈឺជាប់

ក្រោកពីគេងមិនរួច ក្អឹងឆេះផ្ទះពេលស្លាប់ក្នុងភ្លើង ព្រឹក

ឡើងម្តាយទោទ ទិងបងថ្លៃប្អូនថ្លៃទោទ ទៅឃើញខ្មោច

ភ្លើងពេល នាំគ្នាផុតយកទៅទុកឯវត្ត ។

ទោទទៅចាំផ្លង់ជាងមួយឆ្នាំ វិលទៅស្រុក អ្នកស្រុក

ទិងម្តាយប្រាប់ទោទ ១ បានចុះចិត្តជឿធ្វើបុណ្យដារ

បន្សុកូលទទួលសច្ចករិយាស្លាប់ជាស្រេចហើយ ម្តេចឡើយ

ទៅប្រកាន់ចម្លើយថាជាករិយាខ្លួនទៀត ឬទោទមានករិយា

ឈ្មោះសារិកា២នាក់ក៏មិនមានក្នុងបណ្តឹងទោទ ។

ទោទមានតំនិកខ្លួន កាចលាក់រឿងក្រន់នេះ មិនពណ៌នា

ឲ្យអស់ខុសនឹងច្បាប់កាត់បណ្តឹង ។

ឯក្រង់ទេខអាចជាស្គាល់ចម្លើយដោយវិធី ១០ សណ្ឋាន គ្មាននរណាជួយដឹងផងបានទេ ព្រោះដឹងតែម្នាក់ឯង ។

កាត់សេចក្តី ត្រូវបដិសេធពាក្យទទួលជាអសារ ហើយត្រូវផ្ញើកល់សានក្រមសាលាដើម ជាស្រេចដាច់ខាត ឲ្យទេខបង់ប្រដាប់ក្តី តាមសានក្រមសាលាទក្ត នឹងសាលាទទួលតាមច្បាប់ ។

ចុះនាមលេខាតុលាការសានព្រះរាជា

ព្រះសក្តាសុំទោសឆ្លើយដំណើរតុលាការ ។ ក៏អនុញ្ញាត ព្រះសក្តាខ្ញុំបាទសូមដំណើរប្រសាសន៍ព្រះតេជព្រះគុណ ជាតុលាការបានជ្រាប ដែលតុលាការបានកាត់សេចក្តី បដិសេធពាក្យទទួលខ្ញុំបាទជាអសារ ផ្ញើកល់សានក្រមសាលាដើមជាត្រឹមត្រូវនោះ ខ្ញុំបាទមានសេចក្តីអរ នឹងព្រះតេជព្រះគុណច្រើនណាស់ ព្រោះត្រូវនឹងបំណងចិត្ត ។



ឯហេតុដែលខ្ញុំបាទពុំបានអធិប្បាយ ក្នុងពាក្យបណ្តឹង ត្រង់ពេលដែលខ្ញុំបាទវិលពីចម្បាំងទៅស្រុក ហើយមកការនឹងអ្នកស្រុកប្រាប់ថា ប្រពន្ធខ្ញុំបាទស្លាប់ដោយកើនពេល ខ្ញុំបាទក៏ជឿ បានធ្វើបុណ្យទទួលផលផល់ខ្មោចមែន តែជាជឿដោយសារគេប្រាប់នឹងបានឃើញផ្ទាល់ដោយភ្នែកក៏ទេ ការដែលលាក់រឿងត្រង់នេះ ព្រោះខ្ញុំបាទមានបារម្ភត្រង់សានព្រះរាជាមានប្រាជ្ញាញាណ នឹងព្យានកសេចក្តីកំបាំងដែលល្អិតសុខុម តាមខ្ញុំបាទថ្លែងនេះឃើញ នឹងកាត់សេចក្តីនេះ ឲ្យខ្ញុំបាទឈ្នះចម្លើយតែម្តងនឹងមិនអស្ចារ្យ ព្រោះខ្ញុំបាទស្មានថាគំរេះប្រាជ្ញសានព្រះរាជា ពោះយ៉ាងណាក៏គង់ចេះលើស សាលាជំនុំខត្តក្រៅ ដោយហេតុខេត្តក្រៅតាំងអស់ក្នុងខមរៈប្រទេស លោកអធិបតីសាលានីមួយ ៗ សក្តិយសកំតូចបៀតត្រកិត មិនស្មើនឹងលោកអធិបតីសានព្រះរាជានោះ ។

ខណៈនេះទើបខ្ញុំបាទដឹងច្បាស់ ថាសានព្រះកញ្ញា មិនមានបេះស្ទើ នឹងសាលាខេត្តក្រៅខុសគ្នា១០បានតែ ៦ ឬ ៧ សាលាខេត្តបាសាក់លោកពិភាក្សារៀនខ្ញុំបាទមាន ដំណឹងស្លូតខ្ញុំបាទខ្វះមុននឹងកាត់សេចក្តី បម្រុកតែសានព្រះ អញ្ញា លោកព្រិក្សាតែគ្នាលោកហើយកាត់តែម្តង មិន មានផ្លូវដេញដោលឲ្យកូនក្តីអស់ចិត្តសោះ ។

ខ្ញុំបាទលាក់ពុតខ្វះ ព្រោះចង់ឲ្យទាញចម្លើយក្នុង នានាសាលាប៉ុណ្ណោះទេ ដើម្បីនឹងទុករឿងក្តីនេះ ឲ្យ លឿនក្រៀនទៅដល់យុគលបាទនៃព្រះករុណា ដែលទ្រង់ មានព្រះអញ្ញាទិញថ្ងៃវិនិច្ឆ័យ ឲ្យល្បីឮខ្ញុំទៅថាខ្ញុំបាទជាដើម ចោទ ឬ នាងចពានជាចុងចម្លើយ ឈ្មោះបាញ់ដោយ បន្ទាល់ ខ្លួនឯងហើយសុខចិត្តស្លាប់ចិត្តឥតប្រែពកកទៅ ។

រឿងក្តីខ្ញុំបាទ បើលោកអ្នកមានប្រជាញាណព្យាន កេឲ្យសមនឹងតាមតុលាការ ។ ជាផ្ញើងថ្មីឲ្យក្រទំនឹងគតិ



យុត្តិធម៌ ។ បើខ្ញុំបាទជាតុលាការ នឹងកេឲ្យឃើញ យ៉ាងយូរណាស់២៤ ម៉ោង ។

តាងហ្វាង– " អ្នកឯងកេយ៉ាងម្តេច ក្រៅពីពាក្យ នឹងសំអាងក្នុងច្បាប់ ហើយមិនទាន់ឃើញផង ?

ព្រះសក្ក – " បាទព្រះតេជព្រះគុណ កុំតាងឲ្យបកប្រែពេក ថែកេឃើញ ឯច្បាប់កាត់បណ្តឹង ជាច្បាប់លេងសំខួន ដូចចង្ក្រាក់អ្នកក្រៀនចាប់សំខ្លួនគ្នា មិននាំទៅកាន់យុត្តិធម៌ទេ ដែលនឹងកេឲ្យឃើញពុតខ្ញុំបាទ ឬពុតនាងចពាន ជារៀបឬ ត្រង់ សាលាដើមក្តី សាលានេះក្តី ម៉េចមិនរើស ចំរើរបស់សាលាឲ្យទៅចង្ក លបស្តាប់ឯផ្ទះគូក្តីក្នុងពេល ដែលស្តាប់ឬព្រះតេជព្រះគុណយល់ថា គូក្តីនានាគមនិ យាយគ្នាសោះក្នុងពេលកំពុងក្តី"

ខ្ញុំបាទឃើញនាងនេះកាលណា គាបដឹងផល់ថា នាងនេះពុតត្បើឈើ ដោយអត់បាយឲ្យស្គម ឲ្យគេក្រ

ទៀតឃើញរូប មុខជាល្អបន្ទាប់គេមកដាក់ ហើយយកភ្លើងដុតផ្ទះនាំគ្នាគេ ក្រង់នេះខ្ញុំបាទគ្រាន់តែស្ដាប់ឮ ក៏ត្រូវយកជាប្រមាណ ។

នាងបាតត្រាក់ខ្លួនព្រើត ហើយធ្វើឫកធឹងធឹងទៅវិញ

ព្រះសក្កា — « ខ្ញុំបាទដឹងទៀតនាងនេះមានបើស្រក់ទឹកភ្នែកទឹកដល់ខ្ញុំបាទខ្វះដែរ ព្រោះតាំងពីបានគ្នា ខ្ញុំបាទថ្នមណាស់ បើពេលនេះកុំក្បត់ខ្ញុំបាទ គង់កូនចាហានខ្ញុំបាទហៅលោកស្រីមិនខាន ដែលខ្ញុំបាទអធិប្បាយនេះប្រយោជន៍បាំងពុតបម្រើយឲ្យដឹងខ្លួនកុំនិយាយរឿង ក្រង់កង ទីស្ងាត់ បើធ្លាប់និយាយរឿងយ៉ាងណាឲ្យប្រព្រឹត្តសិនទៅ ក្រែងព្រះករុណាទ្រង់ព្រះតំរិះគេឃើញ ព្រោះរឿងនេះខ្ញុំបាទសូមទោសរាយសូត្រដើមដីកា ដល់ព្រះករុណាទៀត » ។

ខ្ញុំបាទសូមអភ័យទោសចុះ ក្រែងពោលលើស



លោះសូមអនុញ្ញាត ព្រោះខ្ញុំបាទជាមនុស្សអកតញ្ញូណាស់ ដើរធ្វើតែចាំងហាលគ្រាប់ហាលរំសៅ ហាលថ្ងៃហាលភ្លៀងពន់ពេក ទទួលផលលោកដោយដ៏ធូលី ខ្ញុំបាទទីសក្ដិយសតែប៉ុណ្ណោះ មិនដូចពួកព្រះតេជព្រះគុណបានសេចក្ដី ស្រណុកសប្បាយតាំងថ្ងៃយប់ អង្គុយតែក្រោមម្លប់ក្រដាក់តាំងព្រឹកតាំងរសៀល មានរាលថ្ងៃឈប់ឲ្យល្ហើយ ដោយរាគាកាស ទើបប្រាសទុក្ខសោកពេកភ័យ តែព្រះតេជព្រះគុណ គ្មានភ័យដល់សេចក្ដីទុក្ខលំបាកអ្នកក្ដី ដែលគ្នាធ្វើពុំស្មើ ខឹងការរៀបគ្រង់ ហើយលោកអ្នកថ្លឹងបាំងភ្នែក ផ្ញឹងពាល់តែសស់ក្ដីស្រែក្លីឡើងអស់តាំងគោក្របីរសះ ចុះជាខ្ញុំដូរគេព្រោះតែគតក្ដី ព្រះសក្កាលុះឮនៃក្រនិយាយ ហើយក៏លាចុះពីសាលា ក្រោយនោះបានចូលរាយស្គរដីកា ថ្វាយដល់ព្រះករុណាជាអម្ចាស់ជីវិតផែនដី ។

ព្រះបាទសម្តេចព្រះពាមកផាធិបតីទ្រង់តព្រះនេត្រពុត ក្លាយដែលព្រះសក្តាក្រាបទូលសារទុក្ខថ្វាយ ដូចមានទាំង ក្រោយនេះ ។

## សេចក្តីបុតហ្វាយ

សូមព្រះតេជៈដ៏កល់លើត្បូង

សូមព្រះអង្គទាន ក្រាបបង្គំទូលព្រះករុណាជាអម្ចាស់ ជីវិតលើត្បូង ។

សូមទ្រង់ជ្រាប ក្រោមល្អងធូលីព្រះបាទ ។

ខ្ញុំព្រះអង្គព្រះសក្តារុធទេវីក្រៃ មេពាន់គង់ទាហាន ជើងទឹក សូមសារទុក្ខសេចក្តីក្តៅ ដែលតុលាការជាន់ ក្រៅទីផ្កុង ពិភាក្សាអធិករណ៍ របស់ខ្ញុំព្រះអង្គ មិន ត្រង់ទីផ្គត់យុត្តិធម៌ ។

ខ្ញុំព្រះអង្គសូមក្រាបកោតក្រោមម្ទប់ ព្រះពោធិសម្ភារ បារមីនៃល្អងធូលីព្រះបាទ សេចក្តីដូចម្តេច ដូចមាន



គង់ទោទ — ឃាម៉ូយ ហើយនឹងសានក្រមសាលាខេត្ត ថ្មសាក់ជាជាន់ដើម និងសានព្រះអាជ្ញាជាជាន់បន្ទាប់ស្រាប់ៗ

ព្រោះតាំងពីសាលាពិភាក្សាមិនឲ្យខ្ញុំព្រះអង្គ បន្ទោ បង់នៅសេចក្តីទុក្ខក្តៅបាន ដោយគ្មានសេចក្តីចូលក្នុង តិយុត្តិធម៌សោះ ។

ផលតាំងនេះ សូមឲ្យបង្កើតបង្ហាស់ ដល់ព្រះប្រជ្ញា ញាណ នៃព្រះករុណា ដំមាននៅទឹកព្រះទ័យជ្រះថ្លា ត្រជាក់ ដូចទឹកអនោតត្តជាតសព្រះប្រិត កាចបំបាត់ក្តៅ ដោយនូវព្រះអភិម័យហាបារមី ។

ព្រះសេចក្តីដែលខ្ញុំព្រះអង្គ ទោមប្រកាន់ជាខ សំ ខាន់ ត្រង់ខ្ញុំព្រះអង្គអ្នកជាស្គាល់បង្ហាស់ដោយប៉ុយទី ១ នាយសារិកា ភរិយាខ្ញុំព្រះអង្គមែន ។

ត្រង់នេះសូមព្រះគិរិះដោយព្រះបញ្ញាញាណ និងត្រូវពិ សោធឲ្យ កើតតាំងទុលបទៀតហ៊ើងណា ស្រេចនៅ

ទ្រង់ព្រះចិន្តាឲ្យឃើញថាខ្ញុំព្រះអង្គរៀបឬចម្លើយរៀប ខ្ញុំ សូមទូលតាមព្រះរាជកំណត់ចុះហ្វាយ ។

សេចក្តីគួរពុំគួរសូមទ្រង់ករុណាប្រោស

ចុះនាមលេខា

ព្រះករុណាបានទតបប់សេចក្តីចុះហ្វាយ ក៏ទ្រង់មានឲ្យព្រះហស្តទៅដល់អធិបតីសាលព្រះរាជា ឲ្យថ្វាយសំណុំរឿងព្រះសក្កា សាលាក៏នាំក្រាបបង្គំទូលថ្វាយជាប្រញាប់ ។

ឯសណ្តាប់បូកណាស្រុកឡៃតែធ្វើពតិមាន ១ ផ្សេងក្រៅសាលក្រម ទោះកូនក្តី ឬតុលាការនិយាយផងផែកត្រាក់ង ពីការក្រយ៉ាងណា គេក៏កត់ក្រាមិនឲ្យសល់ពាក្យសំដី ហើយដាក់ក្នុងសំណុំរឿង ដើម្បីជាពន្ធូនៃអ្នកពិនិត្យខាងក្រោយ ។

ព្រះករុណា បានទ្រង់ត្រួតពិនិត្យហ្មត់ ១ សេចក្តី តាំង ពីសាលាដាច់ដើមនឹងសាលព្រះអាជ្ញា ព្រមទាំងសេចក្តីតោ



ធ្វើយចម្លើយសាក្សីនិងសេចក្តីពតិមានទ្រង់ទតជាច្រើនសា ។

ទ្រង់ឃើញថាសាលាទាំងនេះតំរិះមិនហ្មត់ចត់សោះ គួរឲ្យព្រះសក្កាដើមចោទរកនឹងផងនឹងដៀលគ្នះ កំមិនទាន់អស់កំហុសតុលាការ ដែលធ្វើខ្ជិលច្រាជ្ញាយកតែបៀតគ្រ គានគិតគាណ៌កត្រាស្រូវគ្គីដែលពឹងមន្ត្រីជាតុលាការ ។

ព្រះអង្គក៏ទ្រង់ពិតាណាមិនបានលេចលាស់ ព្រោះនឹងចាប់កស្តុមិនដល់ពាល់មិនត្រូវ ជល្បូវបើនឹងឲ្យមនុស្សទៅល្បងល្អួងលោមចម្លើយទី ១ ឲ្យចូលមកនៅក្នុងកំង ហើយកាំងកប់គានឲ្យនិយាយឲ្យត្រង់នឹងយក ធ្វើព្រះសំក្រមការជាទោប្រោសប្រាណមុខជានឹងបានការ តែមិនជាទីអស្ចារ្យដូចជាការគេឃើញដោយបន្ទាល់កល់ខ្លួនដូចចោទថា តាំងឃើញបង់ប្រៀបប្រាជ្ញាមួយ ១ ទៀតថា បើកុំតែល្បួងបញ្ញាគកំគង់គេពុំមនុស្សរៀចមិនឃើញ ឬ នឹងឲ្យមនុស្សទៅលបស្តាប់ក្នុងទីស្ងាត់សោក កំចោទរកបើថ្វីអស់ហើយ

យើងមិនគួរដើរតាមគំនិតវា  ព្រះអង្គទ្រង់ពិចារណា តាំងថ្ងៃ
ព្រលប់សង្ស័យថាអាសក្តាវុធវាវៀចទេដឹង ។

ព្រះអង្គនៅទ្រង់ព្រះវិតក្កពេកណាស់  ទើបត្រាស់ប្រើ
កាផ្សាក្រុមព្រះមន្ទីរឲ្យទៅហៅគ្រូក្តីនេះ ចូលគាល់ក្នុងព្រះរាជ
វាំង. ជួបជុំសេវកាមាត្យមានសម្តេចចៅហ្វាទីងលោក
សេនាបតីក្រាបបង្គំគាល់ត្រៀបត្រា ។

ព្រះសក្តាទិនខាងធបាត  នូវប្រលិតគំចូលគាល់តាម
ត្រាស់បង្គាប់ព្រះករុណាក៏ទ្រង់អធិប្បាយ  រាយរឿងឲ្យអស់
លោកសេនាបតីស្តាប់  ហើយទ្រង់មានព្រះតម្រាស់សួរ
ថារឿងយ៉ាងនេះ អស់លោកនឹងត្រូវប្រើប្រាជ្ញាបាយយ៉ាង
ម្តេច  ទើបដឹងកេរៀបត្រង់ឲ្យឃើញ  ព្រោះតោខកាន់ខ្លួន
ឯង  ជាបគ្គាល់តែម្យ៉ាង  ថាស្គាល់ចម្លើយនេះជាករិយា
ចម្លើយប្រពៃតជាប់ថាខ្លួនមិនមែនជាករិយាតោខ  រាជតាំង
សាក្សីមានគ្រាន់ខ្លួនដឹងច្បាស់ឃើញទៀត  សាក្សីក៏សមប្រកប



តាមកំឡាំង ៤ គ្រួតលើសតោខ ។
តែព្រះចង់យោបស់យើងជាអ្នកម្ចាស់ផែនដីចង់ឲ្យក្តាន់បានឈ្នះ
ដោយម្ចាស់សុខចិត្តឲ្យឈ្នះផង  ទើបយុត្តិធម៌  បើម្ចាស់
មិនបានសុខចិត្តឲ្យឈ្នះទេ  ដូចជាទៅឈ្នះតាំងពីរ  ហៅ
ថាឈ្នះដោយកាផ្សាច្បាប់ ។

សម្តេច — «សូមទ្រង់ព្រះមេត្តាប្រោសខ្ញុំព្រះអង្គបាន
ស្តាប់តាមត្រៃព្រះតម្រាស់  ឃើញថាព្រះសក្តាតោខ
បានព្រមសុខចិត្តហើយ  ត្រង់សានព្រះអាជ្ញាឃើញពុត
តោខ  ដឹងថានាងសារិកាស្លាប់នៅក្នុងជាការ» ។

«ហេតុដូចម្តេចបានតោខទៅប្រកាន់ចម្លើយទៀត បើ
ចម្លើយប្រពៃតែដែរ  មានតែភរិយាតោខឈ្មោះសារិកា
៤រូប  ទើបត្រូវសន្តតដល់រូបចម្លើយក្រៅនៃព្រួនឈ្មោះ»

ព្រះករុណា — ថា«  សម្តេចបាប់សំនួនត្រូវហើយ
តែមិនត្រង់តាមយុត្តិធម៌  ព្រោះតោខជាលាក់ពុតត្រង់នេះ

ដើម្បីឲ្យសានព្រះអាជ្ញាកាត់ឲ្យបាញ់ចុះ ទឹងបានឲ្យរឿង
នេះលឿនមកដល់យើងជាម្ចាស់ផែនដី កេពុកគ្គក្ខឲ្យ
ព្រមសុខចិត្តទៀត ពោខបានតាំងជាក្រែងបម្រើយក្លូន
យករោគបមកដុតជួសខ្ទុន ក្រន់នេះយើងក៏សង្ស័យផែ
បានជាគ្រូកេទៀតឲ្យយើញពុតបម្រើយផង សម្តេចគ្រូ
នឹកឲ្យដល់រឿងក៏ឯកកៃគ្រូពៅខ្ទុះ ។

សម្តេចចៅហ្វាឆៅស្មៀប ។

ព្រះករុណាជ្រាបថា សម្តេចចៅហ្វាគន់ចង់កេរឿង
ព្រះសក្តា ដោយហេតុអ្វីមួយទើបក្រាស់សួរព្រះសក្តាថា"

ក្រែងទោសប្រាប់ទើបនឹងព្រោះ ប្រពន្ធឯងក្មេងពេលស្លាប់ទៅ
ហើយឲ្យនិយាយដោយសត្យពិតត្រង់ទៅ...,, ។

សក្កា „សូមទ្រង់ព្រះមេត្តាប្រោស ទើបមើយ
មិនមែនករិយាខ្ញុំព្រះអង្គទេ សូមថ្វាយជីវិត„

ព្រះករុណា— ត្រាស់សួរនាងបពាក „ឯងឬជា
ខ្ញុំនសារិកាប្រពន្ធទោទ? ,,

បពាក- ពាម្ចាស់, ខ្ញុំម្ចាស់មិនមែនសារិកាករិយា
ទោចទេ,, ។

ព្រះករុណា - ព្រលិតទៀត „ឯងឬតាំពង្រ៉ក
សារិកាប្រពន្ធទោទ ?,

ព្រលិត— „សូមទ្រង់ព្រះមេត្តាប្រោស, ខ្ញុំព្រះ
អង្គមិនមែនទេ នាងនេះឈ្មោះបពាក បានផណ្តឹង
រៀបការតាមត្រឹមត្រូវ” ។

ព្រះករុណា— ទ្រង់ព្រះតំរិះមួយស្របក់ ទើបហៅ

ហោចទៅជិតខ្សែបស្នាថា "កាលឯងនៅនឹងគ្នាជាប្តីប្រពន្ធ ចូន បានកេសុីមានសម្បត្តិទ្រព្យឥតវិញ្ញាណ និង វិញ្ញាណជាអ្វីខ្លះ ដែលនៅមានដល់សព្វថ្ងៃនេះ ?,:

ព្រះសក្កា - សូមទ្រង់ព្រះមេត្តាប្រោស របស់បន្តិចបន្តួច ក្រៅពីនេះអស់ទៅនៅតែខ្លួន ឈ្មោះអាពាល ព្រះករុណា ទ្រង់ញាក់ព្រះភក្ត្រហើយថា វត្ថុនោះនៅណាឥឡូវនេះ ?

សក្កា— នៅផ្ទះ ដែលសំណាក់សព្វថ្ងៃនេះ ?

ព្រះករុណា—អើឯងទៅនាំយកមកឥឡូវនេះឲ្យឆាប់ ៗ

សក្កា ក៏ថ្វាយបង្គំលាទៅហៅយកខ្ញុំចូលមក ឯអាពាល បានចូលទៅក្នុងទីធុងព្រះរាជវាំង ចេះតែងើបសំឡឹងមើល ជុំវិញខ្លួន ប្រមុះចេះតែមើលស្រង់ភ្នែកយូរបន្តិច ក៏ដើរទៅពីក្រោយនាងបទុមាហើយក៏ចូលកៀកដើមនាងបទុមា រួចប្រាសដេកពីក្រោយខ្នង នាងនេះមិនបានដឹងផង ព្រោះ



កំពុងតែនឹងភ័យខ្លាចណាស់ បណ្ដានាម៉ឺនទាំងអស់ក៏គ្មាននរណាដឹង ។

ព្រះករុណា "ត្រាស់ហៅក្រុមព្រះនគរបាល ដែលជាមេគុកចូលទៅខ្សែប្រាប់ ហើយពួកនោះក៏ចេញទៅ ស្របក់ចូលវិញ ម្នាក់លីប្រអប់ក៏នឹងកាពិកដែកយកមកទំលាក់ នៅមុខនាងបទុមាក្រៅ ម្នាក់យកដាវបកហួតពីស្រោម បញ្ឈរនៅពីមុខនាងបទុមា ហើយនឹងអាពាល កាលគេទំលាក់ប្រអប់ក្រៅ ក៏ភ្ញាក់ស្លុតមុខហាក់ អាពាល ក៏ក្រោកឡើងក្រាបព្រះ១ហាក់ហើយដេកដូចដែលនៅវិញ ។

ព្រះករុណាក្រោកពីបល្ល័ង្គ ទ្រង់ទៅឈរពីមុខនាងបទុមា ត្រាស់ដោយព្រះសូរសៀងខ្លាំង ថាពេជ្ឈឃាដយកមេនេះទៅប្រហារជីវិតជាមួយនឹងសហាយវា ។

នាងបទុមា · ចិត្តនឹងណាស់ទើបទូលព្រះអង្គទ្រង់ ឃើញ ពីគ្រូខ្ញុំម្ចាស់ច្បាស់យ៉ាងម្ដេច សូមប្រោសឲ្យដឹងសិន

ទើងបានអស់ចិត្ត ?

ព្រះករុណា "បន្ទាល់របស់ឯងឆ្លើយ ប្រាប់ផ្ទាប់ពីក្រោយ ខ្ញុំ ឯងក្រឡេកមើលទៅចុះ ទាននោះក៏ងាកក្រឡេកមើល ទៅក្រោយ ខ្ញុំឃើញអាពាល១ ក្រឡេកមើលវិញ ហើយ បក់កន្ទុយលិតជើង ទាងនោះក៏ក្រាបថ្វាយបង្គំ " ។

ព្រះករុណា–ថា "អាពាលហ្នឹងហើយឬសារិកាម្ចាស់ ឯង អាពាលក៏ក្រាបខ្ទប់ទីងទាងសារិកា ស្ទាបហិមបក់ កន្ទុយហើយលើកចង្កាវ ដាក់លើភ្លៅទាងសារិកា ។ លើក ដៃទីងប្រាន ព្រះករុណាស្រែកឃាត់ថាកុំឲ្យដេញវា សាក្សី នេះមិនស៊ីសំណូកឯងទេ" ។

បណ្ដាទាម៉ឺនតាំងអស់ ក៏ទឹកគោតទីងសរសើរព្រះ ប្រាជ្ញា ព្រះករុណាពេញក្នុងទីចុងព្រះពន្ធពេង ។ ទាង បចាតក្រាបយំហើយទូលថា "ខ្ញុំម្ចាស់សារគោពសូមព្រះអង្គ ទ្រង់ជ្រាប ថាខ្ញុំជាម្ចាស់ឈ្មោះសារិកាពីដើមជាភរិយា



ព្រះសក្កាបែនបានផិតក្បត់ស្វាមី ដោយសេចក្ដីតក់ស្លុតព្រោះ រស់ទីពីនក្នុងគ្រាដែលស្វាមីមិននៅទៅច្បាំងតាំងពី ៦ ខែ ប្រុសសាហាយនេះឈ្មោះសាកយក្លែងក្លាយជាប្រលិត គ្រា នេះបើព្រះអង្គទ្រង់ប្រហារជីវិត ក៏សុខចិត្តទទួលតាមកំ ហុស តែសូមព្រះអង្គទ្រង់ព្រះករុណាទុកអាយុខ្ញុំប្រុសឲ្យ រស់នៅឲ្យបាន ព្រោះមានបុត្រ ១ ទីងគ្នានៅតូចទើបកា- យុបាន ១ ឆ្នាំ គ្រាន់បានថែទាំក្សាបុត្រ "

ព្រះករុណា ក៏មានព្រះជប្រាស់ហៅព្រះសក្កាមកផិត ហើយត្រាស់ថា?

"ឯងសុខចិត្តឲ្យធ្វើទោសទាងនេះត្រឹមណា ឲ្យថា កាមគ្រង់ទៅចុះ ។ សក្កា –" សូមទ្រង់ព្រះមេត្តាប្រោស , ដែលខ្ញុំព្រះអង្គប្ដីទីងពីទាងនេះ ពុំបានតាំងចិត្តជាកាយាជព្យា- បាទទេ គឺប្ដីងចង់លុបឈ្មោះកុំឲ្យគេថាឯងបង្កាច់គេ ។ មិន បែនប្រពន្ធឯង ។ ទៅប្រកាន់" ព្រះករុណា – "ចុះមុន

មុននោះបើឯងចិត្តល្អ ម៉្តេចក៏ទៅប្រកាន់គេពីរ ក្រៅតែ ឃើញស្គាល់ហើយ សៀមទៅមិនបានឬ ?,,

សក្កា– សូមទ្រង់ព្រះមេត្តាប្រោស និស្ស័យស្រឡាញ់មិនទាន់ដាច់ដើរហួសទៅហើយ សម្តេចនាងនេះពេកត្រាក់ឲ្យខ្លួនអណ្តែតមកក្រោយវិញ ១ ព្យាមងើបឡើងឃើញមុខច្បាស់ប្តូតមាត់ ហៅគេប្រពន្ធតែម្តងទៅគេខឹងគេបានទៅជាប់ជារឿងវែង បើពេលនោះនាងនេះនិយាយដោយស្រួលទទួលសុំទោសតែ ១ ម៉ាត់ខ្ញុំព្រះអង្គឥតរវល់សោះ ព្រោះខ្ញុំព្រះអង្គតាំងចិត្តជាក្តីជាតិនេះ មិនសានសេចក្តីកក្រក់ទឹនបៀតបៀនគេ ឲ្យលំបាកដោយកាយវាចាចិត្ត បើនាងនេះមិនក្បត់ផិតស្វាប់ដោយក្តីពេលវែង ខ្ញុំព្រះអង្គតាំងចិត្តមិនយកស្រីទៀតធ្វើភរិយាទេ ព្រោះតែស្វាប់ខ្ញុំព្រះអង្គមិនដែលមានស្រីក្រៅទេ ព្រោះកណិតស្រីណាស់ បើមានហើយមុខជាកណិតវែងមិនខ្វេ ណាកណិតអញ្ចមុន



មិនចង់ឲ្យគេទុក្ខព្រោះខ្លួនទើបទំជៀសឲ្យផុត ,,

ព្រះករុណា– „ចុះសព្វថ្ងៃឯងមិនគិតរកប្រពន្ធទៀតទេឬ ?

សក្កា– “ព្រះករុណាពិសេស រកទៀតបានហើយតែមិនទាន់រៀបការ ។

ព្រះករុណា– ចុះឯងថា បើនាងនេះស្លាប់មែនឯងមិនរកទៀតទេម៉្តេចក៏រក ?,,

សក្កា– “ព្រះករុណាពិសេស ខ្ញុំព្រះអង្គទៅដល់ស្រុកមាតាប្រាប់ថាស្លាប់ក៏ជឿស្រក់ទឹកភ្នែកមួយរំពេច នឹកឃើញថាកូនទើបដាច់ចិត្តរកទៀតព្រះករុណា– “ចុះឥឡូវឯងគិតម្តេចនាងនេះ ?

សក្កា– “សូមទ្រង់ព្រះមេត្តាប្រោស អនុញ្ញាតឲ្យរួចវិលទៅរកប្តី ឲ្យសុខសប្បាយទៅចុះៗ

ព្រះករុណា– “ឯងត្រូវនិយាយផ្ទាល់ខ្លួននាងនេះនឹង